អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

## មាតិកា៖


- ទំហំពាណិជ្ជកម្មទ្វេភាគី កម្ពុជា និងចិន ក្នុងឆ្នាំ ២០២០ មានតម្លៃជិត ៨,២ប៊ីលានដុល្លារអាមេរិក
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានរំពឹងថា ទិន្នផលស្រូវរដូវប្រាំងនឹងទទួលបានចំនួន ២,៦លានតោន ក្នុងឆ្នាំ២០២១
- ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេសប្រចាំត្រីមាសទី៤ ក្នុងឆ្នាំ២០២០
- វិស័យឧស្សាហកម្មរបស់វៀតណាមសម្លឹងឃើញឱកាសនាំចេញអំបោះ និងសម្លៀកបំពាក់កីឡា
- ការនាំចូល និងការនាំចេញរបស់ចិននៅក្នុងខែមករា និងកុម្ភៈខ្ពស់ជាងការរំពឹងទុក
- វិស័យទេសចរណ៍កាណាដាបានរងការប៉ះទង្គិចយ៉ាងខ្លាំង ក្នុងឆ្នាំ២០២០
- សេដ្ឋកិច្ចពិភពលោកអាចងើបឡើងវិញ លុះត្រាតែវ៉ាក់សាំងត្រូវបានចែកចាយដល់ប្រទេសកំពុងអភិវឌ្ឍន៍



ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គីម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមវរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

ចងក្រង និងបូកសរុបដោយ

- ធីម ប៊ុនធឿន ប្រធានការិយាល័យវិភាគចំណូល-ចំណាយ

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ទំហំពាណិជ្ជកម្មទ្វេភាគីកម្ពុជា និងចិន ក្នុងឆ្នាំ២០២០ មានតម្លៃជិត ៨,២ប៊ីលានដុល្លារអាមេរិក



*ប្រភព៖ AMS Central, 2021 (https://ams.com.kh/central/detail/286369)*

ការធ្វើពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងចិន នៅក្នុងឆ្នាំ២០២០ មានទំហំប្រមាណ ៨,១ ប៊ីលានដុល្លារ ដែលបានធ្លាក់ចុះ ៥,២% ធៀបនឹងឆ្នាំ២០១៩។

ការនាំចេញទំនិញរបស់ប្រទេសកម្ពុជាទៅកាន់ប្រទេសចិនក្នុងឆ្នាំ២០២០ មានតម្លៃ១,០៨ប៊ីលានដុល្លារ កើនឡើង ៨,១% ធៀបនឹងឆ្នាំ២០១៩។ រីឯការនាំចូលទំនិញមកកាន់ប្រទេសកម្ពុជា ពីប្រទេសចិនបានធ្លាក់ចុះ ៦,៩% ធៀបនឹងឆ្នាំ២០១៩ដែលនៅត្រឹម ៧,០៣ ប៊ីលានដុល្លារ។ ការធ្លាក់ចុះនៃការនាំចូលទំនិញពីប្រទេសចិន គឺដោយសារតែការថយចុះនៃការនាំចូលវត្ថុធាតុដើមសម្រាប់ផ្គត់ផ្គង់ខ្សែសង្វាក់ផលិតកម្មរោងចក្រកាត់ដេរនៅកម្ពុជា តាមរយៈការដាក់ចេញនូវវិធានការរឹតបន្តឹងច្រកចេញ-ចូលក្រៅប្រទេស និងវិធានការបង្ការជំងឺកូវីដ-១៩ របស់រាជរដ្ឋាភិបាលកម្ពុជា។

ប្រភេទទំនិញរបស់កម្ពុជាសម្រាប់នាំចេញទៅប្រទេសចិនភាគច្រើនជាផលិតផលកសិកម្ម ក្នុងនោះរួមមាន អង្ករ ស្វាយ ដំណាប់ស្វាយ និងដំឡូងមីជាដើម។ ចំណែកឯកម្ពុជានាំចូលពីប្រទេសចិនភាគច្រើនជាផលិតផលឧស្សាហកម្ម និងវត្ថុធាតុដើមសម្រាប់ឧស្សាហកម្មកាត់ដេរ និងសម្ភារសំណង់។

បន្ទាប់ពីប្រទេសកម្ពុជាបានចាប់ផ្តើមអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយប្រទេសចិន វានឹងក្លាយជាឱកាសមួយអាចជំរុញឱ្យបណ្តាសហគ្រាសមកពីបណ្តាប្រទេសផ្សេងៗមកវិនិយោគនៅកម្ពុជា ដើម្បីកែច្នៃផលិតផលកសិកម្មសម្រាប់នាំចេញទៅប្រទេសចិនកាន់តែច្រើន។ ប្រទេសកម្ពុជា និងប្រទេសចិនបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី កាលពីខែតុលា ឆ្នាំ២០២០ ដោយរំពឹងថា កិច្ចព្រមព្រៀងនេះនឹងជំរុញការអភិវឌ្ឍពាណិជ្ជកម្មឱ្យដល់កម្រិតថ្មីមួយ ដែលនាំមកនូវផលប្រយោជន៍កាន់តែច្រើនដល់សហគ្រាស និងប្រជាជននៅក្នុងប្រទេសកម្ពុជា និងប្រទេសចិន៕ *ដោយ សេន ចន្ទូ*

*ប្រភព៖ AMS Central, ចេញផ្សាយថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១*

## ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រំពឹងថាទិន្នផលស្រូវរដូវប្រាំង នឹងទទួលបានចំនួន ២,៦លានតោន ក្នុងឆ្នាំ២០២១



*ប្រភព៖ Khmer times, 2021 (https://www.khmertimeskh.com/50821318/maff-expects-2-6-million-tonnes-of-dry-season-paddy-this-year/)*

យោងតាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទបានបង្ហាញថា៖ ក្នុងឆ្នាំ២០២០នេះ ស្រូវប្រាំងត្រូវបានដាំដុះលើផ្ទៃដីជាង ៦៤២ ៥៨៣ហិចតា ដែលបានកើនឡើង៤០% លើសផែនការ ដែលបានគ្រោងទុក ត្រឹមតែ ៤៥៩ ២០០ហិចតា ទោះបីជា ប្រទេសកម្ពុជា និងប្រទេសដទៃទៀតក្នុងតំបន់ដីសណ្តទន្លេមេគង្គបានជួបប្រទះបញ្ហាកម្ពស់ទឹកសាប មានកម្រិតទាបក៏ដោយ។

ខេត្តចំនួន៥ ក្នុងចំណោមរាជធានី ខេត្ត ទាំង២៥ បានគ្របដណ្តប់ដោយការដាំដុះស្រូវរដូវប្រាំងច្រើនជាងគេ ដែលក្នុងនោះរួមមាន ខេត្តព្រៃវែងសម្រេចបានការដាំដុះលើផ្ទៃដីចំនួន ១១១ ២៧៩ហិចតា ខេត្តតាកែវសម្រេចបាន ១០៧ ៣៧៧ហិចតា ខេត្តកំពង់ធំ ចំនួន៧៦ ៩៥៦ហិចតា ខេត្តកណ្តាល បានចំនួន ៥៤ ០៤៧ហិចតា និងខេត្តបន្ទាយមានជ័យ បានចំនួន ៥០ ៥១១ហិចតា។ ទន្ទឹមនឹងនេះ កសិករនៅតំបន់ផ្សេងៗទៀតទូទាំងប្រទេស ក៏កំពុងដាំដុះ និងធ្វើការប្រមូលផលស្រូវប្រាំងផងដែរ។

លោករដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ បានលើកឡើងថា គិតត្រឹមខែមីនានេះ ទិន្នផលស្រូវរដូវប្រាំងប្រមូលផលបាន ១,៤លានតោន នៅលើផ្ទៃដីដាំដុះចំនួន ៣២៥ ៦១៣ហិចតា ស្មើនឹងជាង៥០% នៃទិន្នផលសរុប ដែលក្នុងនោះមួយហិចតាប្រមូលផលបានចំនួន ៤,៤៣តោន។ ទិន្នផលស្រូវរដូវប្រាំងសរុបត្រូវបានរំពឹងថា នឹងទទួលបានចំនួន ២,៦លានតោន ក្នុងឆ្នាំ២០២១នេះ។

ក្នុងរយៈពេលពីរខែដំបូងនៅក្នុងឆ្នាំ២០២១នេះ កម្ពុជាបាននាំចេញស្រូវទៅកាន់ប្រទេសវៀតណាម ចំនួន ៧០៧,៦ពាន់តោន ដែលក្នុងនោះតួលេខនាំចេញជាផ្លូវការមានចំនួន ៣៤៥,៦ពាន់តោន ក្នុងតម្លៃចន្លោះពី ៩៥០រៀលទៅ ១ ១៧០រៀល ក្នុងមួយគីឡូក្រាម នេះបើយោងតាមរបាយការណ៍របស់អគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ៕

*ដោយ មុំ ចិន្តា*

*ប្រភព៖ Khmer times ចេញផ្សាយថ្ងៃទី០៦ ខែមីនា ឆ្នាំ២០២១*

## តារាងប្រចាំសប្តាហ៍៖ ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេសប្រចាំត្រីមាសទី៤ ក្នុងឆ្នាំ២០២០

យោងតាមទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជាបានបង្ហាញថា៖ នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២០

នេះ រដ្ឋបាលថ្នាក់ជាតិ ប្រមូលចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស បានចំនួនសរុប ៦៤៩,៤ប៊ីលានរៀល ដែលមានកំណើន ប្រមាណជា ៣២% ធៀបនឹងត្រីមាសទី៣។

| ចំណូល(គិតជាប៊ីលានរៀល) | ត្រីមាសទី១ | ត្រីមាសទី២ | ត្រីមាសទី៣ | ត្រីមាសទី៤ |
|---|---|---|---|---|
| **ពន្ធលើ ពាណិជ្ជកម្មក្រៅប្រ ទេស** | **621.0** | **448.9** | **493.4** | **649.4** |
| **កំណើ ន%** | | **-28%** | **10%** | **32%** |
| ពន្ធ និងអាករលើការនាំចូល | 614.6 | 446.4 | 488.3 | 639.5 |
| កំណើន% | | -27% | 9% | 31% |
| ពន្ធ និងអាករលើការនាំចេញ | 6.5 | 2.5 | 5.1 | 9.9 |
| កំណើន% | | -61% | 103% | 93% |

ជាក់ស្តែង ចំណូលពន្ធ និងអាករលើការនាំចូលប្រមូលបានប្រមាណជាង ៦៣៩,៥ប៊ីលានរៀល នៅក្នុងត្រីមាសទី៤ ឆ្នាំ២០២០នេះមានកំណើនប្រហែល៣១% ធៀបនឹងត្រីមាសទី៣។

ស្របពេលជាមួយគ្នានេះដែរ ការប្រមូលចំណូលពន្ធ និងអាករលើការនាំចេញក្នុងត្រីមាសទី៤មានចំនួន ៩,៩ប៊ីលានរៀល ដែលមានកំណើនយ៉ាងខ្លាំងប្រមាណជា ៩៣% បើធៀបនឹងត្រីមាសមុន៕ *ដោយៈ មិត្ត ចន្ទី* *ប្រភពៈ* *តារាងប្រតិបត្តការហិរញ្ញវត្ថុឆ្នាំ២០២០ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### វិស័យឧស្សាហកម្មរបស់ប្រទេសវៀតណាមសម្លឹងឃើញឱកាសនាំចេញអំបោះ និងសម្លៀកបំពាក់កីឡា



*ប្រភព៖ Viet Name News, 2021 ( https://vietnamnews.vn/economy/896275/vietnamese-textile-industry-sees-huge-export-opportunities-in-yarn-sportswear.html )*

ឧស្សាហកម្មវាយនភ័ណ្ឌ និងសម្លៀកបំពាក់នៅប្រទេសវៀតណាមអាចបន្តអាជីវកម្មរបស់ខ្លួនរហូតឆ្លងផុតរលកទីបីនៃកូវីដ-១៩ ដោយសារពួកគេបានសម្រេចចិត្តផលិតម៉ាស និងឧបករណ៍ការពារខ្លួនសម្រាប់លក់។ នាពេលខាងមុខ វិស័យនេះ នឹងផ្តោតលើការផលិតអំបោះ និងសម្លៀកបំពាក់កីឡាវិញម្តង ដោយសារតម្រូវការម៉ាសក្រណាត់ និងឧបករណ៍ការពារខ្លួនមានការថយចុះ ពោលគឺតម្រូវការសម្ភារៈទាំងនោះកំពុងតែត្រលប់ទៅរកកម្រិតមុនពេលមានជំងឺកូវីដ-១៩ ដោយសារតែនៅពេលនេះ ពិភពលោកបានរកឃើញវ៉ាក់សាំងការពារកូវីដ-១៩ ជាបន្តបន្ទាប់។

សហគ្រាសវាយនភ័ណ្ឌ និងដេរស្បែកជើងនៅប្រទេសវៀតណាម ផ្លាស់ប្តូរផែនការផលិតរបស់ខ្លួននៅពេលមានតម្រូវការ និងទីផ្សារថ្មី។ ពួកគេធ្វើការសម្រេចចិត្តផ្អែកទៅតាមបទពិសោធន៍ ដែលបានជួបប្រទះនៅក្នុងកំលុងពេលកូវីដ-១៩។ ដូចនេះ ពួកគេផ្លាស់ប្តូរផែនការពីព្រោះក្នុងកំលុងពេលមានមេរោគកូរ៉ូណា មនុស្សចាប់

ផ្តើមយល់ដឹងពីសារៈសំខាន់នៃការធ្វើលំហាត់ប្រាណច្រើនជាងមុន។

យោងតាម Euromonitor International នៅក្នុងឆ្នាំ ២០២០ តម្រូវការសម្លៀកបំពាក់កីឡានៅទូទាំងពិភពលោកថយចុះតែប្រមាណ៨% ដែលប្រវត្តិនៃការធ្លាក់ចុះទាបបំផុត នៃឧស្សាហកម្មនេះមានដល់ ១៦% ។

អត្រាកំណើនប្រចាំឆ្នាំ នៃទីផ្សារសម្លៀកបំពាក់កីឡានៅក្នុងរយៈពេល៥ឆ្នាំចុងក្រោយនេះ កើនឡើងដល់ ៦,៥% ពោលគឺស្មើនឹង ១,៥ ដង នៃកំណើនជាមធ្យមក្នុងវិស័យនេះ។ នៅឆ្នាំ២០២៥ ទីផ្សារសម្លៀកបំពាក់កីឡានៅទូទាំងពិភពលោក អាចនឹងមានតម្លៃស្មើនឹង ៤៧៩ ប៊ីលានដុល្លារ ។

យោងតាមសមាគមឧស្សាហកម្មវាយនភ័ណ្ឌ និងសម្លៀកបំពាក់វៀតណាមបានឱ្យដឹងថា វៀតណាមទទួលបានការបញ្ជាទិញរហូតដល់ចុងខែមេសា ដែលភាគច្រើនជាសម្លៀកបំពាក់កីឡា។ គួររម្លឹកផងដែរថា តាមរយៈកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី (The EU-Vietnam Free Trade Agreement) ចាប់ពីខែសីហា ឆ្នាំទៅ វៀតណាមបានបន្ថយពន្ធលើការនាំចូលសម្លៀកបំពាក់ទៅកាន់សហគមន៍អឺរ៉ុប ដល់ទៅ ៧០ពិន្ទុភាគរយ ដែលធ្វើឱ្យវិស័យនេះទទួលបានអត្ថប្រយោជន៍ គួរឱ្យកត់សម្គាល់ ពីការកាត់បន្ថយពន្ធ៕ *ដោយ វង្ស ច័ន្ទស្មើដារា*

*ប្រភព៖ Viet Name News ចេញផ្សាយថ្ងៃទី៧ ខែមីនា ឆ្នាំ ២០២០១*

## ការនាំចូល និងការនាំចេញរបស់ចិននៅក្នុងខែមករា និងកុម្ភៈខ្ពស់ជាងការរំពឹងទុក




*ប្រភព៖ South China Morning Post, 2021, (https://www.scmp.com/economy/china-economy/article/3124406/china-january-february-exports-and-imports-stronger-expected)*

ការនាំចេញ និងការនាំចូលរបស់ចិននៅក្នុងខែមករា និងកុម្ភៈខ្ពស់ជាងការរំពឹងទុក បង្ហាញថាសេដ្ឋកិច្ចពាណិជ្ជកម្មរបស់ចិនងើបឡើងវិញយ៉ាងរហ័សនៅដើមឆ្នាំនេះ។ ដោយសារតែនៅក្នុងត្រីមាសទី១ ឆ្នាំ២០២១ តម្រូវការនាំចេញផលិតផលចិនដូចជា៖ សម្ភារៈវេជ្ជសាស្ត្រ សម្ភារៈការិយាល័យ និងឧបករណ៍កំសាន្តមានការកើនឡើង ហើយតម្រូវការនៅក្នុងស្រុកមានកំណើនខ្ពស់ ព្រោះសេដ្ឋកិច្ចចិនចាប់ផ្តើមងើបឡើងវិញបន្ទាប់ពីទទួលរងផលប៉ះពាល់ដោយសារកូវីដ-១៩។

ការនាំចេញរបស់ចិននៅក្នុងខែមករា និងខែកុម្ភៈមានកំណើនដល់ទៅ ៦០,៦%ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន និងខ្ពស់ជាងកំណើនខែធ្នូ ឆ្នាំ២០២០ ដែលមានចំនួន១៨,១% និងខ្ពស់ជាងលទ្ធផលរំពឹងទុករបស់

អ្នកវិភាគ Bloomberg ដែលបានព្យាករណ៍ថា ការនាំចេញរបស់ចិនអាចនឹងមានកំណើនត្រឹមតែ ៣៨% ប៉ុណ្ណោះ។

រីឯការនាំចូលរបស់ចិននៅក្នុងខែមករា និងកុម្ភៈ កើនឡើង ២២,២%ធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន ខ្ពស់ជាងខែធ្នូ ដែលមានកំណើន៦,៥% និងខ្ពស់ជាងការព្យាករណ៍របស់អ្នកវិភាគ Bloomberg ដែលបានរំពឹងទុកថា ការនាំចូលរបស់ចិនអាចនឹងមានកំណើនត្រឹមតែ ១៥% ប៉ុណ្ណោះ។

គួររំលឹកថា ការនាំចូលរបស់ចិនកាលពីខែមករា និងកុម្ភៈ ឆ្នាំ២០២០ ធ្លាក់ចុះចំនួន ៤%។ ប៉ុន្តែពេលនេះ ទំហំពាណិជ្ជកម្មរបស់ចិននៅក្នុងខែមករា និងខែកុម្ភៈ មានអតិរេកដល់ទៅ ១០៣,២៥ប៊ីលានដុល្លារ ធៀបទៅនឹងទំហំពាណិជ្ជកម្មរបស់ចិនកាលពីខែធ្នូ ដែលមានទំហំ ៧៨,១៨ប៊ីលានដុល្លារ។

គួរបញ្ជាក់ថា កំណើននេះមិនមែនពឹងផ្អែកតែទៅលើតម្រូវការក្នុងស្រុកប៉ុណ្ណោះទេ។ ប៉ុន្តែ វាពឹងផ្អែកលើតម្រូវការរបស់អ្នកប្រើប្រាស់នៅតាមបណ្តាប្រទេសដែលមានសេដ្ឋកិច្ចធំៗមួយចំនួនទៀតដែរដូចជាៈ សហគមន៍អឺរ៉ុប និងសហរដ្ឋអាមេរិក។

គួរកត់សំគាល់ផងដែរថា ការនាំចេញរបស់ចិនទៅសហរដ្ឋអាមេរិកនៅកំលុងពេលពីរខែនេះកើនឡើង ៨៧,៣% រីឯការនាំចូលពីសហរដ្ឋអាមេរិកមកកាន់ប្រទេសចិនកើនឡើង ៦៦,៤%។ ទិន្នន័យនេះបង្ហាញថាទំនាក់ទំនងពាណិជ្ជកម្មរវាងប្រទេសទាំងពីរនៅមានគម្លាតនៅឡើយ។ *ដោយ វង្ស ច័ន្ទស្មើដារា*

*ប្រភព៖ South China Morning Post ចេញផ្សាយថ្ងៃទី៧ ខែមីនា ឆ្នាំ២០២១*

## សេដ្ឋកិច្ចសកល

### វិស័យទេសចរណ៍នៅកាណាដាបានរងការប៉ះទង្គិចយ៉ាងខ្លាំង ក្នុងឆ្នាំ២០២០



*ប្រភព៖Global Times, Xinhua, 2021 (https://www.global-times.cn/page/202103/1217779.shtml)*

យោងតាមគោលដៅទេសចរណ៍កាណាដា (Destination Canada) វិស័យទេសចរណ៍នៅកាណាដាបានទទួលរងការប៉ះទង្គិចយ៉ាងធ្ងន់ធ្ងរ និងបានធ្វើឱ្យកំណើនសេដ្ឋកិច្ចក្នុងវិស័យនេះធ្លាក់ចុះគួរឱ្យកត់សម្គាល់ និងមិនធ្លាប់មានពីមុនមក ដែលការណ៍នេះបង្កឡើងដោយសារវិបត្តិជំងឺរាតត្បាតកូវីដ-១៩។ ក្នុងនោះដែរ បើគិតចាប់ពីខែមេសា ដល់ ខែវិច្ឆិកា ឆ្នាំ២០២០ ចំនួនអ្នកធ្វើដំណើរតាមផ្លូវអាកាសបានធ្លាក់ចុះ ៩១% រីឯចំណូលពីការស្នាក់នៅបានធ្លាក់ចុះ ៧១%។ ទន្ទឹមនេះដែរ សម្រាប់ខែមិថុនា ចំនួនភ្ញៀវទេសចរណ៍ ដែលធ្វើដំណើរតាមផ្លូវអាកាសមានត្រឹមតែ ៤៤០ពាន់នាក់ប៉ុណ្ណោះ ដែលថយចុះចំនួន ៦,៧លាននាក់ទាបជាងកាលពីខែមិថុនា ឆ្នាំ២០១៩។

ដោយឡែក សម្រាប់ចំណូលសណ្ឋាគារនៅឆ្នាំ២០២០ ដែលមានទីតាំងស្ថិតក្នុងក្រុង Toronto, Montreal និង Vancouver ដែលជាក្រុងរងផលប៉ះពាល់ធ្ងន់ធ្ងរ គឺបានបាត់បង់ចំណូលប្រមាណជា ២,៣ប៊ីលានដុល្លារកាណាដា ឬស្មើនឹងការធ្លាក់ចុះ ៧៩% បើធៀបនឹងឆ្នាំ២០១៩។ បន្ថែមពីនេះ បើពិនិត្យមើលស្ថានភាពការងារវិញ អត្រាគ្មានការងារធ្វើក្នុងវិស័យទេសចរណ៍មានអត្រាខ្ពស់ជាងគេក្នុងចំណោមវិស័យផ្សេងៗទៀត ដែលខ្ពស់ជាងអត្រាគ្មានការងារថ្នាក់ជាតិចំនួន ៦,៦% សម្រាប់ឆ្នាំ២០២០។

បើទោះបីជាមានសញ្ញាពីការងើបឡើងវិញនៃសេដ្ឋកិច្ចក៏ដោយ អាជីវកម្មក្នុងវិស័យទេសចរណ៍បានកំពុងតែបន្តជួបផលវិបាកហិរញ្ញវត្ថុ ដែលបណ្តាលឱ្យបិទទ្វារបណ្តោះអាសន្ន ឬក៏អចិន្ត្រៃយ៍។

គួរបញ្ជាក់ផងដែរថា ក្នុងវិស័យទេសចរណ៍ គឺមានអាជីវកម្មធុនតូច និងមធ្យមសរុបមានចំនួន ៩៩% ហើយវិស័យនេះបានជួយទ្រទ្រង់ការងារចំនួន ១៥០ពាន់ការងារ៕

*ដោយ ជា សិរីតន៍*

*ប្រភព៖ Global Times ចេញផ្សាយ ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១*

## សេដ្ឋកិច្ចពិភពលោកអាចងើបឡើងវិញ លុះត្រាវ៉ាក់សាំងត្រូវបានចែកចាយដល់ប្រទេសកំពុងអភិវឌ្ឍន៍




*ប្រភព៖ CNN , 2021, ( https://edition.cnn.com/2021/03/07/perspectives/imf-global-economic-recovery-vaccines-perspectives/index.html )*

យោងតាមការព្យាករណ៍ចុងក្រោយរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) បង្ហាញថា សេដ្ឋកិច្ចសកល នឹងមានកំណើន ៥,៥% ក្នុងឆ្នាំ២០២១ និង៤,២% ក្នុងឆ្នាំ២០២២ ក៏ប៉ុន្តែ IMF បានគូសបញ្ជាក់ផងដែរថា ការងើបឡើងរបស់សេដ្ឋកិច្ច នឹងមានសភាពលំបាក ហើយត្រូវការរយៈពេលវែងដែលមិនមានភាពប្រាកដប្រជា។

នៅក្នុងកំលុងការប្រជុំរវាងរដ្ឋមន្ត្រីហិរញ្ញវត្ថុ និងទេសាភិបាលធនាគារកណ្តាល នៃប្រទេស G20 ថ្មីៗនេះ គេបានធ្វើការកត់សម្គាល់ឃើញថា ថ្វីបើសេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍ និងប្រទេសដែលមានសេដ្ឋកិច្ចកំពុងរីកលូតលាស់ខ្លាំងមួយចំនួនតូចបានងើបឡើងវិញឆាប់រហ័ស ក៏ប៉ុន្តែ ប្រទេសកំពុងអភិវឌ្ឍន៍ ត្រូវការរយៈពេលវែង ដើម្បីស្តារសម្បទាសេដ្ឋកិច្ចរបស់ខ្លួនឡើងវិញ ហើយនឹងអាចបង្កជាហានិភ័យធំមួយ ដែលមិនត្រឹមតែធ្វើឲ្យសោកនាដកម្មមនុស្សជាតិកាន់តែធ្ងន់ធ្ងរប៉ុណ្ណោះទេ តែក៏នឹងបង្កផលប៉ះពាល់សេដ្ឋកិច្ចទៅដល់ប្រទេសដែលងាយរងគ្រោះបំផុតដែរ។

ទន្ទឹមគ្នានេះ IMF បានព្យាករណ៍ថា ចំណូលសម្រាប់មនុស្សម្នាក់នៅចុងឆ្នាំ២០២២ នឹងមានចំនួន១៣% ទាបជាងកម្រិតមុនមានវិបត្តិ សម្រាប់ប្រទេសអភិវឌ្ឍន៍ និង១៨% សម្រាប់ប្រទេសមានចំណូលទាប និង២២% សម្រាប់ប្រទេសមានសេដ្ឋកិច្ចកំពុងរីកលូតលាស់ និងប្រទេសកំពុងអភិវឌ្ឍន៍ (មិនគិតបញ្ចូលប្រទេសចិន) ដែលលទ្ធផលនេះ បានបង្ហាញថា ប្រជាជនរាប់លាននាក់ក្នុងប្រទេសកំពុងអភិវឌ្ឍន៍ នឹងធ្លាក់ចូលក្នុងភាពក្រីក្រធ្ងន់ធ្ងរ។ ការណ៍នេះ ក៏បានបង្ហាញឱ្យឃើញថា គម្លាតប្រាក់ចំណូលរវាងប្រទេសជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍន៍ចំនួន១១០ ដែលត្រូវបានប៉ាន់ស្មានកាលពីមុនថានឹងអាចបំពេញរវាងឆ្នាំ២០២០ ទៅ ឆ្នាំ២០២២នោះ នឹងមានតែប្រទេសចំនួន ៥២ប៉ុណ្ណោះ ដែលអាចតាមទាន់ក្នុងរយៈពេលដែលកំណត់នេះ។ កត្តានេះ មួយផ្នែកបណ្ដាលមកពីលទ្ធភាពក្នុងការទទួលបានវ៉ាក់សាំងមានភាពមិនស្មើគ្នារវាងប្រទេសនីមួយៗ។ ម្យ៉ាងទៀត ប្រទេសមួយចំនួន គឺទទួលរងផលប៉ះពាល់ខ្លាំងដោយសារតែសេដ្ឋកិច្ចពឹងផ្អែកលើវិស័យទេសចរណ៍ និងការនាំចេញប្រេង រីឯប្រទេសមួយចំនួន គឺដោយសារតែថវិកាមានកម្រិត។

ដូច្នេះ ដើម្បីដោះស្រាយបញ្ហាវិសមភាពចំណូល បង្កើនកំណើនសេដ្ឋកិច្ច និងការងារ កត្តាអាទិភាពចំនួនបី គួរត្រូវបានយកចិត្តទុកដាក់ក្នុងការដោះស្រាយ ដែលរួមមាន៖ ១) បន្តខិតខំដើម្បីបញ្ចប់វិបត្តិសុខភាព ២) ប្រយុទ្ធប្រឆាំងនឹងវិបត្តិសេដ្ឋកិច្ច និង៣) គាំទ្រប្រទេសដែលងាយរងគ្រោះ។ វាជាការចាំបាច់ណាស់ ដែលប្រទេសក្រីក្រទទួលបានការគាំទ្រដែលប្រទេសទាំងនោះត្រូវការ។ ការមិនយកចិត្តទុកដាក់លើប្រទេសក្រីក្រ នឹងមិនត្រឹមតែបង្កវិសមភាពនោះទេ តែក៏នឹងបង្ហាញពីការគម្រាមកំហែងធំមួយទៅកាន់ស្ថិរភាពសង្គម និងសេដ្ឋកិច្ចសកលផងដែរ៕

*ដោយ ជា សិរីរតន៍*

*ប្រភព៖ CNN ចេញផ្សាយ ថ្ងៃទី៧ ខែមីនា ឆ្នាំ២០២១*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្ដាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្ដាហ៍ខាងមុខនេះ រួមមាន៖ ការបញ្ជាទិញគ្រឿងយន្ត និងតុល្យភាពពាណិជ្ជកម្មរបស់ប្រទេសជប៉ុន តុល្យភាពពាណិជ្ជកម្មរបស់ប្រទេសឥណ្ឌា ការវិនិយោគមូលបត្របំណុលបរទេសនៅសហរដ្ឋអាមេរិក សន្ទស្សន៍ថ្លៃផ្ទះនៅប្រទេសអូស្ត្រាលី ទិន្នផលសំណង់នៅតំបន់ចាយប្រាក់អឺរ៉ូ សន្ទស្សន៍ថ្លៃផ្ទះថ្មីរបស់ប្រទេសកាណាដា ទុនបម្រុងអន្តរជាតិរបស់ប្រទេសទួរគី ទុនបម្រុងអន្តរជាតិរបស់ប្រទេសឥណ្ឌា និងប្រាក់កម្ចីសុទ្ធវិស័យសាធារណៈរបស់ចក្រភពអង់គ្លេស៕

ខាងក្រោម គឺជាប្រតិទិនដែលនាយកដ្ឋានស្រាវជ្រាវថវិកានឹងបន្តតាមដាននៅសប្ដាហ៍ក្រោយ៖

<u>ថ្ងៃចន្ទ ទី១៥ ខែមីនា ឆ្នាំ២០២១</u>

- ការបញ្ជាទិញគ្រឿងយន្តរបស់ប្រទេសជប៉ុនធៀបនឹងឆ្នាំមុន សម្រាប់ខែមករា
- តុល្យភាពពាណិជ្ជកម្មរបស់ប្រទេសឥណ្ឌាសម្រាប់ខែកុម្ភៈ

ថ្ងៃអង្គារ ទី១៦ ខែមីនា ឆ្នាំ២០២១

- ការវិនិយោគមូលបត្របំណុលបរទេសនៅសហរដ្ឋអាមេរិក សម្រាប់ខែមករា
- សន្ទស្សន៍ថ្លៃផ្ទះនៅប្រទេសអូស្ត្រាលី ធៀបនឹងត្រីមាសមុន សម្រាប់ត្រីមាសទី៤

ថ្ងៃពុធ ទី១៧ ខែមីនា ឆ្នាំ២០២១

- តុល្យភាពពាណិជ្ជកម្មរបស់ប្រទេសជប៉ុន សម្រាប់ខែកុម្ភៈ
- ទិន្នផលសំណង់នៅតំបន់ចាយប្រាក់អឺរ៉ូ ធៀបនឹងឆ្នាំមុន សម្រាប់ខែមករា

ថ្ងៃព្រហស្បតិ៍ ទី១៨ ខែមីនា ឆ្នាំ២០២១

- សន្ទស្សន៍ថ្លៃផ្ទះថ្មីរបស់ប្រទេសកាណាដា ធៀបនឹងខែមុន សម្រាប់ខែកុម្ភៈ
- ទុនបម្រុងអន្តរជាតិរបស់ប្រទេសទួរគី សម្រាប់ថ្ងៃទី១២ ខែមីនា

ថ្ងៃសុក្រ ទី១៩ ខែមីនា ឆ្នាំ២០២១

- ទុនបម្រុងអន្តរជាតិរបស់ប្រទេសឥណ្ឌា សម្រាប់ថ្ងៃទី១២ ខែមីនា
- ប្រាក់កម្ចីសុទ្ធវិស័យសាធារណៈរបស់ចក្រភពអង់គ្លេស សម្រាប់ខែកុម្ភៈ